84.78		ម៉ាស៊ីនរៀបចំ កែច្នៃថ្នាំជក់ ដែលគ្មានចែង ឬបញ្ចូលក្នុងទីតាំងណាមួយនៃជំពូកនេះទេ ។	**Machinery for preparing or making up tobacco, not specified or included elsewhere in this chapter.**					
	8478.10	- ម៉ាស៊ីន :	- Machinery :					
	8478.10.10	- - ប្រើចរន្តអគ្គិសនី	- - Electrically operated	u	15	0	10	0
	8478.10.20	មិនប្រើចរន្តអគ្គិសនី	- - Not electrically operated	u	15	0	10	0
	8478.90	- គ្រឿងបន្លាស់ :	- Parts :					
	8478.90.10	- - នៃម៉ាស៊ីនប្រើចរន្តអគ្គិសនី	- - Of electrically operated machines	kg	15	0	10	0
	8478.90.20	- - នៃម៉ាស៊ីនមិនប្រើចរន្តអគ្គិសនី	- - Of non electrically operated machines	kg	15	0	10	0
84.79		ម៉ាស៊ីន ឧបករណ៍មេកានិក ដែលមានមុខងារផ្សេងៗ គ្មានចែង ឬដាក់នៅក្នុងទីតាំងណាមួយ នៃជំពូកនេះទេ ។	**Machines and mechanical appliances, having individual functions, not specified or included elsewhere in this chapter.**					
	8479.10	- ម៉ាស៊ីនសំរាប់ការងារសាធារណៈ សំណង់ ឬការងារស្រដៀងគ្នា :	- Machinery for public works, building or the like :					
	8479.10.10	- - ប្រើចរន្តអគ្គិសនី	- - Electrically operated	u	15	0	10	0
	8479.10.20	- - មិនប្រើចរន្តអគ្គិសនី	- - Not electrically operated	u	15	0	10	0
	8479.20	- ម៉ាស៊ីនសំរាប់ចំរាញ់ ឬរៀបចំខ្លាញ់សត្វ ប្រេងបន្លែ ឬរុក្ខជាតិ :	- Machinery for the extraction or preparation of animal or fixed vegetable fats or oils :					
		- - ប្រើចរន្តអគ្គិសនី :	- - Electrically operated :					
	8479.20.11	- - - ម៉ាស៊ីនសំរាប់ផលិតប្រេងដូងប្រេង	- - - Machinery for making palm oil	u	15	0	10	0
	8479.20.19	- - - ផ្សេងទៀត	- - - Other	u	15	0	10	0
		- - មិនប្រើចរន្តអគ្គិសនី :	- - Not electrically operated :					
	8479.20.21	- - - ម៉ាស៊ីនសំរាប់ផលិតប្រេងដូងប្រេង	- - - Machinery for making palm oil	u	15	0	10	0

	8479.20.29	- - - ផ្សេងទៀត	- - - Other	u	15	0	10	0	
	8479.30	- ម៉ាស៊ីនសង្កត់សំរាប់ធ្វើបន្ទះក្តារតូចៗ ឬសំណង់សរសៃឈើ ឬវត្ថុធាតុមានសរសៃដទៃទៀត និងម៉ាស៊ីនផ្សេងទៀតសំរាប់ច្រលក់ឈើ ឬឆ្នុក :	- Presses for the manufacture of particle board or fibre building board of wood or other ligneous materials and other machinery for treating wood or cork :						
	8479.30.10	- - ប្រើចរន្តអគ្គិសនី	- - Electrically operated	u	15	0	10	0	
	8479.30.20	- - មិនប្រើចរន្តអគ្គិសនី	- - Not electrically operated	u	15	0	10	0	
	8479.40	- ម៉ាស៊ីនវេញពួរ និងខ្សែកាប :	- Rope or cable-making machines :						
	8479.40.10	- - ប្រើចរន្តអគ្គិសនី	- - Electrically operated	u	15	0	10	0	
	8479.40.20	- - មិនប្រើចរន្តអគ្គិសនី	- - Not electrically operated	u	15	0	10	0	
	8479.50.00	- យន្តសាស្ត្រឧស្សាហកម្ម ដែលគ្មានចែង ឬបញ្ចូលក្នុងជំពូកនេះ	- Industrial robots, not elsewhere specified or included	u	15	0	10	0	
	8479.60.00	- ម៉ាស៊ីនបង្អួតខ្យល់ត្រជាក់	- Evaporative air coolers	u	15	0	10	0	
		- ម៉ាស៊ីន និងឧបករណ៍មេការនិកផ្សេងទៀត :	- Other machines and mechanical appliances :						
	8479.81	- - សំរាប់លោហធាតុ រួមទាំងសរសៃលួសរុំបូប៊ីនអគ្គិសនីប្រើខ្សែ :	- - For treating metal, including electric wire coil-winders :						
	8479.81.10	- - - ប្រើចរន្តអគ្គិសនី	- - - Electrically operated	u	15	0	10	0	
	8479.81.20	- - - មិនប្រើចរន្តអគ្គិសនី	- - - Not electrically operated	u	15	0	10	0	
	8479.82	- - ម៉ាស៊ីនលាយ ច្របាច់ បំបែក កិន បឹស រែង កម្រាប សំរាប់វាយបញ្ចូលគ្នា ឬសំរាប់កូរ :	- - Mixing, kneading, crushing, grinding, screening, sifting homogenising, emulsifying or stirring machines :						
	8479.82.10	- - - ប្រើចរន្តអគ្គិសនី	- - - Electrically operated	u	15	0	10	0	
	8479.82.20	- - - មិនប្រើចរន្តអគ្គិសនី	- - - Not electrically operated	u	15	0	10	0	
	8479.89	- - ផ្សេងទៀត :	- - Other :						

	8479.89.20	- - - ម៉ាស៊ីនស្វ័យសំរាប់តំលើងស៊ីភីយូ ម៉េនបត ដែលផ្ទុកក្នុងធុងឬប្រអប់ផ្លាស្ទិក ។ ឧបករណ៍សំរាប់ការកែជាថ្មីនៃល្បាយគីមីប្រើប្រាស់ក្នុង ផលិតកម្មផ្ទាំងសៀគ្វីបោះពុម្ព។ ឧបករណ៍សំអាតគីមីលើផ្ទៃផ្ទាំងសៀគ្វីបោះពុម្ព សៀគ្វីខ្សែលួសក្នុងពេលផលិត ។ ម៉ាស៊ីនស្វ័យប្រវត្តិ សំរាប់ជំនួស ឬយកចេញនៃធាតុនៃសៀគ្វីបោះពុម្ព និងសបស្រ្តេតផ្សេងទៀត។ ឧបករណ៍កត់ត្រាសំរាប់ការធ្វើឱ្យ តំរង់ជួរនៃ ផ្ទាំងសៀគ្វីបោះពុម្ព ឬសៀគ្វីបោះពុម្ពតម្លើងរួចក្នុងផលិតកម្ម។	**- - - Machinery for assembling central processing unit (CPU)** daughter boards in plastic cases or housings; apparatus for the regeneration of chemical solutions used in the manufacture of printed circuit boards or printed wiring boards; equipment for mechanically cleaning the surfaces of printed circuit boards or printed wiring boards during manufacturing; automated machines for the placement or the removal of components or contact elements on printed circuit boards or printed wiring boards or other substrates; registration equipment for the alignment of printed circuit boards or printed wiring boards or printed circuit assemblies in the manufacturing process;	u	15	0	10	0	
	8479.89.30	- - - ប្រើដោយចរន្តអគ្គិសនីផ្សេងទៀត	- - - Other electrically operated	u	15	0	10	0	
	8479.89.40	- - - មិនប្រើដោយចរន្តអគ្គិសនីផ្សេងទៀត	- - - Other not-electrically operated	u	15	0	10	0	
	8479.90	- ភាគ បំណែកឬគ្រឿងបន្លាស់ :	- Parts :						
	8479.90.20	- - ភាគ បំណែកនៃទំនិញទីតាំងរងលេខ ៨៤៧៩.៨៩.២០	- - Of the goods of subheading 8479.89.20	kg	15	0	10	0	
	8479.90.30	- - នៃម៉ាស៊ីនប្រើចរន្តអគ្គិសនី	- - Of electrically operated machines	kg	15	0	10	0	
	8479.90.40	- - នៃម៉ាស៊ីនមិនប្រើចរន្តអគ្គិសនី	- - Of non electrically operated machines	kg	15	0	10	0	
84.80		ប្រអប់ចាក់ពុម្ព សំរាប់ឡូស្លដែក ។ ពុម្ពធម្មតា ពុម្ពគំរូ ពុម្ពសំរាប់ដែក (ក្រៅពីពុម្ពបន្ទះ ដែកស្ទិត) លោហៈកាបួរ កែវ វត្ថុធាតុ ជ័រ ឬ ប្លាស្ទិក ។	**Moulding boxes for metal foundry; mould bases; moulding patterns; moulds for metal (other than ingot moulds), metal carbides, glass, mineral materials, rubber or plastics.**						
	8480.10.00	- ប្រអប់ចាក់ពុម្ព សំរាប់ឡូស្លដែក	- Moulding boxes for metal foundry	kg	15	0	10	0	
	8480.20.00	- ពុម្ពធម្មតា	- Mould bases	kg	15	0	10	0	
	8480.30	- ពុម្ពគំរូ :	- Moulding patterns :						
	8480.30.10	- - ទង់ដែង	- - Of copper	kg	15	0	10	0	
	8480.30.90	- - ផ្សេងទៀត	- - Other	kg	15	0	10	0	
		- ពុម្ពសំរាប់លោហធាតុ និង លោហធាតុកាបួរ :	- Moulds for metal or metal carbides :						

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០០៦ សហវ

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៧

សេចក្តីសំរេច
ស្តីពី
ការកែសម្រួល និងបំពេញបន្ថែមនូវមុខងារ និងភារកិច្ចរបស់ ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

៚ ✽ ៚

អនុលោមតាមប្រកាសលេខ ៩២០ សហវ គរ ប្រក ចុះថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ទីចាត់ការគយ និងរដ្ឋាករ និងដើម្បីឆ្លើយតបទៅនឹងសំណូមពរការងារចាំបាច់របស់ទីចាត់ការគយ និងរដ្ឋាករ ក្នុងគោលបំណងរក្សានូវតុល្យភាពនៃតម្រូវការនៃការបង្កើនប្រសិទ្ធភាពការងារគយ និងរដ្ឋាករ និងការបន្តអនុវត្តកិច្ចសម្រួលពាណិជ្ជកម្មនោះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរេចកែសម្រួល និងបំពេញបន្ថែមជាបណ្តោះអាសន្ននូវមុខងារ និងភារកិច្ចរបស់ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដូចខាងក្រោម :

១- ប្រគល់មុខងារ និងភារកិច្ចបន្ថែមឱ្យការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបន្ទុកគ្រប់គ្រង ត្រួតពិនិត្យដោយផ្ទាល់នូវកិច្ចដំណើរការទីស្នាក់ការគយ និងរដ្ឋាករផ្សេងទៀតតាមអាកាសយានដ្ឋានអន្តរជាតិនានា ក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ប្រគល់ភារកិច្ចរៀបចំធ្វើសំណើសុំផ្លាស់ប្តូរមន្ត្រីរាជការគយ និងរដ្ឋាករក្រោមឱវាទ ពីអាកាសយានដ្ឋានអន្តរជាតិមួយទៅអាកាសយានដ្ឋានអន្តរជាតិមួយទៀត តាមរូបភាពវិល្លជុំ និងតាមសំណូមពរការងារជាក់ស្តែង ដាក់សុំការពិនិត្យ និងសំរេចពីប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ។

៣- ទីចាត់ការគយ និងរដ្ឋាករ ត្រូវចាត់ចែង ផ្សព្វផ្សាយ និងអនុវត្តតាមខ្លឹមសារសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- សាលាខេត្ត ក្រុងពាក់ព័ន្ធ "ដើម្បីជូនជ្រាប"
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៥.០៧.១៤១ ប្រ.ក

ប្រកាស
ស្តីពី
រចនាសម្ព័ន្ធ និងមុខងារ-ភារកិច្ចរបស់នាយកដ្ឋានប្រតិបត្តិការ

ទេសាភិបាលធនាគារជាតិ នៃ កម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៤៤ ចុះថ្ងៃទី ០៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការតែងតាំងឯកឧត្តម ជា ចាន់តូ ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងប្រកាសលេខ ធ៨.៩៨-៣៨៥ប្រក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៨ ស្តីពីរចនាសម្ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា និងមុខងារ-ភារកិច្ចរបស់បណ្តាអង្គភាពក្រោមឱវាទ
- យោងតាមការអនុម័តរបស់អង្គប្រជុំក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០០៧

សំរេច

ប្រការ ១.- រៀបចំរចនាសម្ព័ន្ធ និងកំណត់មុខងារ-ភារកិច្ចរបស់នាយកដ្ឋានប្រតិបត្តិការនិងការិយាល័យក្រោមឱវាទដូចខាងក្រោម ។

ប្រការ ២.- នាយកដ្ឋានប្រតិបត្តិការ ស្ថិតនៅក្រោមចំណុះអគ្គនាយកដ្ឋាន មានមុខងារ-ភារកិច្ចចំបង១គឺ ÷

- គ្រប់គ្រងប្រព័ន្ធទូទាត់ និងសភាផាត់ទាត់
- បើកគណនីឱ្យស្ថាប័នរដ្ឋ ឬ អង្គភាពរដ្ឋបាលកណ្តាលដូចជា រតនាគារជាតិជាដើម
- បើកគណនីឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលមានការអនុញ្ញាតពីធនាគារកណ្តាលឱ្យធ្វើអាជីវកម្ម
- បើកគណនីឱ្យអង្គការអន្តរជាតិ
- ធ្វើប្រតិបត្តិការ និងចុះកិច្ចបញ្ជិកាជួញដូរមូលប័ត្ររបស់រដ្ឋាភិបាល ជាមួយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- សិក្សាការផ្តល់និងតាមដានឥណទានរដ្ឋាភិបាល និងប្រមូលបំណុល

- ធ្វើប្រតិបត្តិការទិញ-លក់មូលប័ត្រដែលបោះផ្សាយដោយរដ្ឋាភិបាល
- ផ្តល់ឥណទាន និងបុនហិរញ្ញប្បទានដល់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនិងអនុវត្តគោលនយោបាយអត្រាការប្រាក់។

នាយកដ្ឋានប្រតិបត្តិការត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយ ឬ ច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

ប្រការ ៣.- រចនាសម្ព័ន្ធរបស់នាយកដ្ឋានប្រតិបត្តិការត្រូវបានរៀបចំឱ្យមានការិយាល័យចំនួន ៤ នៅក្រោមឱវាទដូចមានអង្គការលេខភ្ជាប់ជាឧបសម្ព័ន្ធគឺ ÷

១-ការិយាល័យគ្រប់គ្រងគណនី គ្រប់គ្រងផ្ទាល់នូវ ÷
- ផ្នែកគ្រប់គ្រងគណនីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ
- ផ្នែកគ្រប់គ្រងគណនីក្រសួង-ស្ថាប័នថ្នាក់កណ្តាល
- ផ្នែកគ្រប់គ្រងគណនីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ផ្នែកត្រួតពិនិត្យប្រតិបត្តិការ ។

២-ការិយាល័យឥណទាន និងគ្រប់គ្រងមូលប័ត្រ គ្រប់គ្រងផ្ទាល់នូវ ÷
- ផ្នែកឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ផ្នែកឥណទានរដ្ឋាភិបាល និងប្រមូលបំណុល
- ផ្នែកគ្រប់គ្រងប្រព័ន្ធបញ្ជីមូលប័ត្រ
- ផ្នែកគ្រប់គ្រងការដេញថ្លៃ។

៣-ការិយាល័យសភាផាត់ទាត់ គ្រប់គ្រងផ្ទាល់នូវ ÷
- ផ្នែកទូទាត់
- ផ្នែកឯកសារ ។

៤-ការិយាល័យជួរក្រោយ គ្រប់គ្រងផ្ទាល់នូវ ÷
- ផ្នែកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ និងទិន្នន័យ
- ផ្នែកផ្ទៀងផ្ទាត់បញ្ជី
- ផ្នែករបាយការណ៍ និងចងក្រងឯកសារ
- ផ្នែករដ្ឋបាល ។

ការិយាល័យ និងផ្នែកនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប អមដោយអនុប្រធានមួយ ឬ ច្រើនរូប ជួយធ្វើការតាមការចាំបាច់ ។

ប្រការ ៥._ការិយាល័យគ្រប់គ្រងគណនី ដែលគ្រប់គ្រងគណនីរបស់ស្ថាប័នរដ្ឋ ឬ អង្គភាពរដ្ឋបាលកណ្តាល និងរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ មានភារកិច្ចតាមផ្នែកដូចតទៅ ÷

១- ផ្នែកគ្រប់គ្រងគណនីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ ÷

- គ្រប់គ្រងការបើក-បិទគណនីជូនដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ
- គ្រប់គ្រងគណនីគ្រប់ប្រភេទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារជាតិ
- គ្រប់គ្រងគណនីប័ណ្ណរតនាគាររបស់រតនាគារជាតិ
- ផ្តល់របាយការណ៍ស្ថានភាពគណនី ប្រកាសឥណពន្ធ និងប្រកាសឥណទាន ជូនដល់អតិថិជនជាម្ចាស់គណនី
- គ្រប់គ្រងគណនីផ្ទៃក្នុងដែលទាក់ទងនឹងគណនីរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរតនាគារជាតិ ។

២- ផ្នែកគ្រប់គ្រងគណនីក្រសួង-ស្ថាប័នថ្នាក់កណ្តាល ÷

- គ្រប់គ្រងការបើក-បិទគណនីជូនដល់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល
- គ្រប់គ្រងគណនីគ្រប់ប្រភេទរបស់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល
- ផ្តល់របាយការណ៍ស្ថានភាពគណនី ប្រកាសឥណពន្ធ និងប្រកាសឥណទាន ជូនដល់អតិថិជនជាម្ចាស់ម្ចាស់គណនី
- គ្រប់គ្រងគណនីផ្ទៃក្នុង ដែលទាក់ទងនឹងគណនីរបស់ក្រសួង-ស្ថាប័នថ្នាក់កណ្តាល ។

៣- ផ្នែកគ្រប់គ្រងគណនីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ÷

- គ្រប់គ្រងការបើក-បិទគណនីជូនដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រប់គ្រងគណនីគ្រប់ប្រភេទរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ផ្តល់របាយការណ៍ស្ថានភាពគណនី ប្រកាសឥណពន្ធនិងប្រកាសឥណទានជូនដល់អតិថិជនជាម្ចាស់គណនី
- គណនាអត្រាការប្រាក់បញ្ញើមានកាលកំណត់ របស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ធ្វើប្រតិបត្តិការទិញ-លក់រូបិយប័ណ្ណតាមរយៈគណនីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រប់គ្រងគណនីផ្ទៃក្នុង ដែលទាក់ទងនឹងគណនីរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ ⁄

៤- ផ្នែកត្រួតពិនិត្យប្រតិបត្តិការ ÷

- ត្រួតពិនិត្យនូវការចុះបញ្ជីលើរាល់ប្រតិបត្តិការដែលត្រូវបានធ្វើដោយផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣ តាមការផ្ទៀងផ្ទាត់ទិន្នន័យក្នុងកុំព្យូទ័រជាមួយឯកសារភ្ជាប់ និងស្ថានភាពគណនី ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវ រួចហើយបញ្ជូនត្រឡប់មកវិញ ដើម្បីឱ្យអ្នកផ្តើមប្រតិបត្តិការក្នុងផ្នែកទី១ ផ្នែកទី២ និងផ្នែកទី៣ ធ្វើការងារបន្ត (Post និង Print សក្ខីប័ត្រ)។

ប្រការ ៥.- ការិយាល័យឥណទាន និងគ្រប់គ្រងមូលប័ត្រ ដែលអនុវត្តការងារទាក់ទងទៅនឹងការផ្តល់ហិរញ្ញប្បទាន បុនហិរញ្ញប្បទាន ការប្រមូលបំណុល ការគណនាអត្រាការប្រាក់ ប្រតិបត្តិការទិញ លក់មូលប័ត្រ ដែលបោះផ្សាយដោយរដ្ឋាភិបាល មានភារកិច្ចតាមផ្នែកដូចតទៅ ÷

១- ផ្នែកឥណទានគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ÷

- គ្រប់គ្រង តាមដានការផ្តល់ឥណទាន ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គ្រប់គ្រង តាមដានប្រតិបត្តិការបុនហិរញ្ញប្បទាន និងប៉ង់ស្យុងចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- គណនាអត្រាការប្រាក់គោលរបស់ធនាគារជាតិនៃកម្ពុជា
- គណនាអត្រាការប្រាក់ហិរញ្ញប្បទាន បុនហិរញ្ញប្បទានដែលបានផ្តល់ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- ផ្សព្វផ្សាយរាល់គោលនយោបាយ ឬ បញ្ញាណែនាំរបស់ធនាគារជាតិនៃកម្ពុជា ចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ។

២- ផ្នែកឥណទានរដ្ឋាភិបាល និងប្រមូលបំណុល ÷

- គ្រប់គ្រងការផ្តល់ឥណទានចំពោះរដ្ឋាភិបាល
- ប្រមូលបំណុលពីឥណទានចំពោះរដ្ឋាភិបាល
- តាមដាន ជំរុញការប្រមូលបំណុលពីឥណទានដែលដក់សល់ ។

៣- ផ្នែកគ្រប់គ្រងប្រព័ន្ធបញ្ជីមូលប័ត្រ ÷

- កត់ត្រាក្នុងប្រព័ន្ធកុំព្យូទ័រនូវទិន្នន័យពាក់ព័ន្ធនឹងបរិវិសកម្ម (ការចុះឈ្មោះទិញ) និងការដេញថ្លៃមូលប័ត្រ
- ចេញរាល់លិខិតស្នាមពាក់ព័ន្ធដល់ការដេញថ្លៃ និងការកាន់កាប់មូលប័ត្រ
- គ្រប់គ្រងការទិញ-លក់មូលប័ត្រផ្សេងៗទៀត ដែលបោះផ្សាយដោយរដ្ឋាភិបាល ។

៤- ផ្នែកគ្រប់គ្រងការដេញថ្លៃ ÷

- រៀបចំកម្មវិធីដេញថ្លៃមូលប័ត្រ ផ្អែកតាមការជូនដំណឹងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ជូនដំណឹងដេញថ្លៃ ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- ជូនដំណឹង ប្រកាសលទ្ធផលដេញថ្លៃ និងរាយការណ៍អំពីលទ្ធផលទទួលបានជូនថ្នាក់ដឹកនាំ ។

ប្រការ ៦.- ការិយាល័យសភាផាត់ទាត់ ដែលគ្រប់គ្រងប្រព័ន្ធទូទាត់ មានភារកិច្ចតាមផ្នែកដូចតទៅ ÷

១- ផ្នែកទូទាត់ ÷

- គ្រប់គ្រងសភាផាត់ទាត់ដែលបង្កើតឡើងដោយធនាគារជាតិនៃកម្ពុជា
- ដឹកនាំការផាត់ទាត់ប្រចាំថ្ងៃ ចំពោះមូលប័ត្រ ផលប័ត្រពាណិជ្ជ និងមធ្យោបាយទូទាត់ដូចជាមូលប្បទានប័ត្រជាដើម ។

២- ផ្នែកឯកសារ ÷

- សហការរៀបចំបទដ្ឋានរួម សំរាប់ការទូទាត់ក្នុងរង្វង់សមាជិកសភាផាត់ទាត់ឱ្យមានសុវត្ថិភាព
- តំកល់ទុកនូវរាល់ឯកសារផាត់ទាត់
- ធានាប្រតិបត្តិការកុំព្យូទ័រ ។

ប្រការ ៧.- ការិយាល័យជួរក្រោយ ដែលគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ និងទិន្នន័យនៃនាយកដ្ឋានទាំងមូល ផ្ទៀងផ្ទាត់កិច្ចបញ្ជិកា រៀបចំរបាយការណ៍ និងចងក្រងឯកសារ មានភារកិច្ចតាមផ្នែកដូចតទៅ ÷

១- ផ្នែកគ្រប់គ្រងប្រព័ន្ធកុំព្យូទ័រ និងទិន្នន័យ ÷

- បើកម៉ាស៊ីនដើម្បីដំណើរការប្រព័ន្ធ និងបិទម៉ាស៊ីនពេលឈប់ដំណើរការប្រព័ន្ធ
- បញ្ចូលថ្ងៃឈប់សំរាកប្រចាំឆ្នាំ ទៅក្នុងប្រព័ន្ធកុំព្យូទ័រ
- គ្រប់គ្រងការបញ្ចូលថ្ងៃខែ នៃប្រតិបត្តិការ
- គ្រប់គ្រងការបញ្ចូលអត្រាប្តូរប្រាក់ អត្រាការប្រាក់
- ត្រួតពិនិត្យ និងកែតំរូវកំហុសឆ្គងនៃប្រតិបត្តិការ ដែលបង្កឡើងដោយអ្នកធ្វើប្រតិបត្តិការ
- ធ្វើការបិទបញ្ជីចុងថ្ងៃ ក្រោយពីបញ្ចប់ប្រតិបត្តិការប្រចាំថ្ងៃ ប្រចាំគ្រា
- ធ្វើការបិទបញ្ជីចុងខែ និងបិទបញ្ជីចុងឆ្នាំ
- ចំលងទិន្នន័យ (Back Up Data) តាមនីតិវិធីសុវត្ថិភាពសំរាប់រក្សាទុកប្រចាំថ្ងៃ
- ផ្តល់របាយការណ៍សំរាប់សវនកម្ម (Audit Files) ។

២- ផ្នែកផ្ទៀងផ្ទាត់បញ្ជី ÷

- ផ្ទៀងផ្ទាត់បញ្ជីរាល់ប្រតិបត្តិការប្រចាំថ្ងៃ ដែលត្រូវបានធ្វើដោយគ្រប់ការិយាល័យ
- ផ្ទៀងផ្ទាត់ប្រតិបត្តិការលំអិតប្រចាំថ្ងៃលើបញ្ជីវិភាគប្រចាំថ្ងៃ
- ពិនិត្យតុល្យភាពនៃប្រតិបត្តិការសរុបឥណពន្ធនិងឥណទាន ។

៣- ផ្នែករបាយការណ៍ និងចងក្រងឯកសារ ÷

- ធ្វើរបាយការណ៍សំរាប់ប្រព័ន្ធប្រតិបត្តិការផ្ទេរប្រាក់អន្តរជាតិ (International Transactions Reporting System)
- ធ្វើរបាយការណ៍ស្ថានភាពគណនីប្រចាំថ្ងៃ
- ធ្វើរបាយការណ៍ស្ថិតិនៃប្រតិបត្តិការប្រចាំថ្ងៃ
- ធ្វើរបាយការណ៍ទិញ-លក់រូបិយប័ណ្ណតាមរយៈគណនីប្រចាំថ្ងៃ
- ចងក្រងសក្ខីប័ត្រ ដើម្បីបញ្ជូនទៅនាយកដ្ឋានគណនេយ្យ
- កសាងរបាយការណ៍សំរាប់សវនកម្ម (Audit Files)
- ធ្វើរបាយការណ៍លទ្ធផលការងាររបស់នាយកដ្ឋាន តាមរបបរាយការណ៍ប្រចាំខែ ត្រីមាស ឆមាស នព្វមាស ឆ្នាំ
- កសាងគំរោងផែនការប្រចាំគ្រាកំណត់ ។

៤- ផ្នែករដ្ឋបាល ÷

- តាក់តែង ចាត់បញ្ជូន និងរក្សាទុក នូវរាល់លិខិតឬឯកសារទាក់ទងផ្ទៃក្នុង ក៏ដូចចេញទៅខាងក្រៅ
- ទទួល បញ្ជូនតាមមុខសញ្ញា និងរក្សាទុកនូវរាល់លិខិត ឬឯកសារដែលផ្ញើចូល
- ដោះស្រាយ និងផ្គត់ផ្គង់សម្ភារៈ មធ្យោបាយបំរើការងារ តាមសេចក្តីត្រូវការជាក់ស្តែង
- គ្រប់គ្រងបញ្ជីវត្តមានមន្ត្រីបុគ្គលិក រៀបចំកម្មវិធីការងារសំរាប់ថ្នាក់ដឹកនាំ និងធានាពិធីការចំពោះភ្ញៀវ និងពិធីផ្សេងៗ ។

ប្រការ ៨.- ក្រៅពីភារកិច្ចដែលមានចែងនៅរាល់ប្រការខាងលើនេះ ថ្នាក់ដឹកនាំនាយកដ្ឋាន ការិយាល័យ និងផ្នែកនីមួយៗ ត្រូវអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់លើប្រគល់ជូន ។

ប្រការ ៩.- ក្នុងការបំពេញភារកិច្ចរបស់ខ្លួន មន្ត្រីបុគ្គលិកនាយកដ្ឋានប្រតិបត្តិការ ត្រូវរក្សាដាច់ខាតនូវការសម្ងាត់វិជ្ជាជីវៈ អនុលោមតាមមាត្រា១៦ និងមាត្រា៧១ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ។

ប្រការ ១០._ប្រកាសលេខ ធ១.០១-៦៧ ប្រក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០០១ ស្តីពីរចនាសម្ព័នរបស់នាយកដ្ឋានប្រតិបត្តិការ និងមុខងារ-ភារកិច្ចរបស់ការិយាល័យក្រោមឱវាទ ត្រូវទុកជានិរាករណ៍ ។

ប្រការ ១១._អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន-អង្គភាពក្រោមឱវាទធនាគារជាតិនៃកម្ពុជាព្រមទាំងនាយកដ្ឋានសាមីត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ១២._ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០៧

ទេសាភិបាល

ជា_ចាន់តូ

<u>កន្លែងទទួល:</u>

-ដូចប្រការ១១

" ដើម្បីអនុវត្ត "

-កាលប្បវត្តិ

-ឯកសារ

<u>ចម្លងជូន:</u>

-សមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា

-ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាបជាព័ត៌មាន "

-នាយកដ្ឋានរដ្ឋបាលទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីចុះផ្សាយក្នុងរាជកិច្ច "

ធនាគារជាតិ នៃ កម្ពុជា
នាយកដ្ឋានប្រតិបត្តិការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អង្គភាពលេខ

ស្តីពី

រចនាសម្ព័ន្ធរបស់នាយកដ្ឋានប្រតិបត្តិការ

(ឧបសម្ព័ន្ធនៃប្រកាសលេខ ធ៥.០៧-១៤១ ប្រក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៧)



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy
លេខ : ៩៧៦ ឧ.រ.ថ ប្រក

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ៣៣៩៥/០៧ គ.វ.ក ចុះថ្ងៃទី២៩.០៨.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើ របស់ក្រុមហ៊ុន ស្កាយ ណាយ អ៊ិនធើណេសិនណល ចុះថ្ងៃទី២១.០៨.២០០៧

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន ស្កាយ ណាយ អ៊ិនធើណេសិនណល (SKY NICE INTERNATIONAL CO., LTD.) តំណាងដោយ លោក WANG, MAO- CHUAN សញ្ជាតិចិន (តៃវ៉ាន់) អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ 200204598 ចុះថ្ងៃទី២៦.១១.២០០២ បង្កើតរោងចក្រ "ផលិតស្បែកជើង" ដែលមានឈ្មោះថា " ស្កាយ ណាយ អ៊ិនធើណេសិនណល (SKY NICE INTERNATIONAL)" ដែលមានទីតាំងស្ថិតនៅ "សួនឧស្សាហកម្ម Wilson " អាគារ A & B ផ្លូវជាតិលេខ៤ ភូមិផ្សារកំបូល ឃុំកំបូល ស្រុកអង្គស្នួល ខេត្តកណ្តាល ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវរៀបចំរោងចក្រ ទៅតាមប្លង់ដែលបានតម្កល់ទុក នៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតស្បែកជើង" ហើយត្រូវផ្តល់ទិន្នន័យ និង របាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្ម របស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកណ្តាល និងប្រធានក្រុមហ៊ុន ស្កាយ ណាយ អ៊ិនធើណេសិនណល ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកណ្តាល
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

Ministry of Industry, Mines and Energy

លេខ : ៩៣៧ ឧរថ.កទ-ប្រក.

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កញ្ញា ឆ្នាំ ២០០៧

ប្រកាស

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត / ០៧០៤/ ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/ ០១៩៦/ ០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២១៨៥ /០៧ ត.វ.ក ចុះថ្ងៃទី០៤.០៧.២០០៧ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើ របស់ក្រុមហ៊ុន អាណា វ៉ៃធ័រ អេន ស្មាយល័រ ប៊ីវើរេច ខូអិលធីឌី ចុះថ្ងៃទី២២.០៦.២០០៧

សម្រេច

ប្រការ១: អនុញ្ញាតឱ្យក្រុមហ៊ុន អាណា វ៉ៃធ័រ អេន ស្មាយល័រ ប៊ីវើរេច ខូអិលធីឌី (ANA WATER AND SMILER BEVERAGE CO., LTD.) តំណាងដោយ លោក PHAM VANLAC សញ្ជាតិវៀតណាម អាយុ៤០ឆ្នាំ កាន់លិខិតឆ្លងដែនលេខ A1023611B ចុះថ្ងៃទី១១.០២.២០០៤ បង្កើតរោងចក្រ "ផលិតស្រាបៀរ ទឹកក្រូច និងទឹកបរិសុទ្ធ" ដែលមានឈ្មោះថា " អាណា វ៉ៃធ័រ អេន ស្មាយល័រ ប៊ីវើរេច ខូអិលធីឌី (ANA WATER AND SMILER BEVERAGE CO., LTD.)" មានទីតាំងស្ថិតនៅ ភូមិត្រកួន និងភូមិត្រពាំងចារ ឃុំក្រឡា និងឃុំអំពិល ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

ប្រការ២: មុនចាប់ផ្តើមដំណើរការរោងចក្រ ក្រុមហ៊ុនត្រូវជូនដំណឹង មកក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឱ្យបានមុនរយៈពេល១៥ថ្ងៃ និងត្រូវផ្តល់ប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន មកក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងរយៈពេល២ខែ យ៉ាងយូរ ។

ប្រការ៣: រោងចក្រនេះត្រូវបានអនុញ្ញាតឱ្យ "ផលិតស្រាបៀរ ទឹកក្រូច និងទឹកបរិសុទ្ធ" ហើយត្រូវផ្តល់ទិន្នន័យ និងរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ តាមមាត្រា១៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និង សិប្បកម្ម ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៤: ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ៥: ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ផ្លាស់ប្តូរទីតាំងរោងចក្រ ឬ បង្កើតសាខារោងចក្រ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាត ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ៦: ក្រុមហ៊ុន ត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឱ្យបានម៉ឺងម៉ាត់ នូវច្បាប់ និងបទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្ម របស់ក្រុមហ៊ុន ។

ប្រការ៧: ក្រុមហ៊ុន ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ក្នុងគោលបំណងអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាព ។

ប្រការ៨: ក្នុងករណីរោងចក្រផ្អាកដំណើរការជាប់១ឆ្នាំក្នុងរយៈពេល១២ខែ ឬ ប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ ។

ប្រការ៩: អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ខេត្តកំពង់ចាម និងប្រធានក្រុមហ៊ុន អាណា វិតធ័រ អេន ស្វាយល័រ ប៊ីវរេច ខូអិលធីឌី ត្រូវអនុវត្តប្រកាសនេះ តាមមុខការរៀង១ខ្លួន ។

ប្រការ១០: ប្រកាសនេះមានអនុភាពតតិយត្តិ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ស៊ុយ សែម

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រាជកិច្ច
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
-ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-សាលាខេត្តកំពង់ចាម
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៩ " ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

លេខៈ ២១៦ ... កប/ប្រ.ក

លិខិតចូល
ថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០០៧

ប្រកាស

ស្តីពី

ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍

+++

រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០១០០/០០៧ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០០ ស្តីពីការបង្កើត អាជ្ញាធរជាតិប្រយុទ្ធ នឹងជំងឺអេដស៍
-បានឃើញអនុក្រឹត្យលេខ ៥២ អនក្រ.បកចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
-យោងលិខិតលេខ ១៦២ គ.ក.ប.វ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីករណីសុំចាត់បញ្ជូនសមាជិក - សមាជិកាក្រុមប្រឹក្សានយោបាយ ០១រូប និងក្រុមប្រឹក្សាបច្ចេកទេសមេរោគអេដស៍/ជំងឺអេដស៍ ០១រូប របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-យោងតាមការចាំបាច់របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ស ម្រេ ច

ប្រការ ១.-

បង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ដែលមានអក្សរកាត់ថា **គ.ប.ជ.អ** ដើម្បីបំរើឱ្យផលប្រយោជន៍ការងារអេដស៍ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ប្រការ ២.-

គណៈកម្មាធិការនេះមានតួនាទី និងភារកិច្ច ÷

១.ជាជំនួយការឱ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈដើម្បីសិក្សាស្រាវជ្រាវ បង្កើតផែនការយុទ្ធសាស្ត្រ ផែនការការងារ និងអនុវត្តនូវផែនការសកម្មភាពកម្មវិធីអេដស៍ដល់ កម្មករ និយោជិត និយោជក ពលករទេសន្តរប្រវេសន៍ តាមសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ជនចំណាកស្រុក និងបុគ្គលិកមន្ត្រីរាជការស្ថិតនៅក្រោមឱវាទក្រសួង ។

២.ចូលរួមសហការសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីស្វែងរកប្រភពធនធាន ថវិកា សម្ភារៈ បច្ចេកទេសពីអង្គការជាតិ អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តផែនការសកម្មភាពឱ្យបានជោគជ័យ ។

៣. អប់រំផ្សព្វផ្សាយដល់ពលករចល័តទាំងក្នុង និងក្រៅប្រទេស មុនពេលចាកចេញ និងពេលត្រឡប់មកវិញដើម្បីទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ជាពិសេសពលករដែលបានទៅបំពេញការងារនៅក្រៅប្រទេស ។

៤. បង្កើនការចូលរួមយ៉ាងសកម្ម របស់អ្នកផ្ទុកមេរោគអេដស៍ និងអ្នករងផលប៉ះពាល់ ដោយសារជំងឺអេដស៍ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់កម្មករ និយោជិតនៅតាមរោងចក្រ សហគ្រាស គ្រឹះស្ថាន ។

៥. ផ្តល់ការគាំទ្រដល់ស្ត្រី/កុមារ ទាំងផ្នែកសំភារៈ ស្មារតី និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាពិសេសស្ត្រី/កុមារដែលផ្ទុកមេរោគអេដស៍ ឬអ្នកទទួលរងផលប៉ះពាល់ដោយសារមេរោគអេដស៍/ជំងឺអេដស៍ ។

៦.ត្រួតពិនិត្យ និងវាយតំលៃលើលទ្ធផលអនុវត្តគោលនយោបាយ គោលការណ៍ ផែនការកម្មវិធីបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងបូកសរុបលទ្ធផលការងារអេដស៍ប្រចាំឆ្នាំ ជូនក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ប្រការ ៣.-

សមាសភាពគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ មានដូចតទៅ÷

១.លោកជំទាវ	**ឡូញ់ ចន្ថា**	រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	ប្រធាន
២. ឯកឧត្តម	**អ៊ុំ មាន**	អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
៣.ឯកឧត្តម	**សូ សាមុត**	អនុរដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
៤. លោកវេជ្ជ.	**ឈឹម យុទ្ធសំភី**	អនុប្រធាននាយកដ្ឋានពេទ្យការងារ	សមាជិកអចិន្ត្រៃយ៍
៥. លោក	**សាលី មុនី**	អនុប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក	សមាជិក
៦. លោកស្រី	**ជា សុខនី**	អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងនីតិកម្ម	សមាជិក
៧. លោក	**គឹម ចិមិត្ត**	អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ	សមាជិក
៨.លោក	**គាម ម៉ារិន្ទ័យ៉ា**	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ	សមាជិក
៩. លោក	**ជុំ មុំ**	អនុប្រធាននាយកដ្ឋានអធិការកិច្ចការងារ	សមាជិក
១០ លោក	**តូច ទុន្នី**	អនុប្រធាននាយកដ្ឋានវិវាទការងារ	សមាជិក
១១. លោក	**ជួប ណារ៉ាត់**	អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម	សមាជិក
១២. លោក	**សួន ស៊ីឡេង**	អនុប្រធាននាយកដ្ឋានសន្តិសុខសង្គម	សមាជិក
១៣. លាកស្រី	**ឱុខ សុភាព**	អនុប្រធាននាយកដ្ឋានការងារកុមារ	សមាជិក
១៤. លោកស្រិ	**នាង សុខរ៉ាស៊ី**	អនុប្រធាននាយកដ្ឋានពេទ្យការងារ	សមាជិក
១៥. លោក	**ហ៊ុង ស៊ីដេត**	អនុប្រធាននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ	សមាជិក

១៦. លោក **គួន តឹមរ៉ៃឡេន** អនុប្រធាននាយកដ្ឋានស្តង់ដារជាតិសមត្ថភាព សមាជិក

១៧. លោក **គង់ ចំនួនតារា** អនុប្រធាននាយកដ្ឋានព័ត៌មានទីផ្សារការងារ សមាជិក

១៨. លោកស្រី **ម៉ៅ ធីតា** អនុប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង សមាជិក

១៩. លោក **យី គន្ធិដ្ឋា** អនុប្រធាននាយកដ្ឋានពេទ្យការងារ សមាជិក

ប្រការ ៤.-

គណៈកម្មាធិការនេះមានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅនាយកដ្ឋានពេទ្យការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលអាចសហការសម្របសម្រួល ដោះស្រាយរាល់បញ្ហាមេរោគអេដស៍/ជំងឺអេដស៍ និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបំពេញការងាររបស់ខ្លួន ។

ប្រការ ៥.-

គណៈកម្មាធិការនេះ អាចលើកសំណើជូនថ្នាក់ដឹកនាំក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការជ្រើសរើសសមាជិកបន្ថែមទៀត ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនក្នុងករណីចាំបាច់ ។

ប្រការ ៦.-

ប្រកាសលេខ ០២ក.ក.ប.វ/ប្រ.ក ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ ២០០៦ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៧.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគ្រប់អង្គភាពស្ថិតក្រោមឱវាទក្រសួង ស្ថាប័នពាក់ព័ន្ធ និងលោក លោកស្រី ដូចមានចែងក្នុងប្រការ៣ មានភារកិច្ចរៀង១ខ្លួនអនុវត្តតាមប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ,ថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០០៧

រដ្ឋមន្ត្រី

វង សុត

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងពាក់ព័ន្ធ
- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- អង្គការក្រៅរដ្ឋាភិបាល
- ក្រុមហ៊ុនពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- ដូចប្រការ ៧
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

"ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ១៤០៤ អយក.ប្រក

ប្រកាស

ស្តីពីការផ្តាច់អនុវិទ្យាល័យ " **ព្រៃវែង** " ចេញពីឧបសម្ព័ន្ធវិទ្យាល័យ " **ពងទឹក** "

ស្ថិតនៅក្នុង សង្កាត់ ព្រៃវែង ខណ្ឌ ដង្កោ រាជធានីភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ ចុះថ្ងៃទី ២៨ ខែមិនា ឆ្នាំ ២០០៧
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

សំរេច

ប្រការ ១ : អនុញ្ញាតឱ្យផ្តាច់អនុវិទ្យាល័យ " **ព្រៃវែង** " ចេញពីឧបសម្ព័ន្ធវិទ្យាល័យ ពងទឹក ស្ថិតនៅក្នុង សង្កាត់ ព្រៃវែង ខណ្ឌ ដង្កោ រាជធានីភ្នំពេញ ចាប់ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀត តាមអង្គការលេខ នៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០០៧

បណ្ឌិត កុល ផេង

កន្លែងទទួល:
- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាក្រុងភ្នំពេញ " ដើម្បីជាពត៌មាន"
- ដូចប្រការ៤
- កាលប្បវត្តិ-ឯកសារ នា.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ:១២០៨អយក.ប្រក

ប្រ កា ស

ស្តីពីការប្តូរឈ្មោះ អនុវិទ្យាល័យ " ចាក់អង្រែ " ទៅជា អនុវិទ្យាល័យ " ហ៊ុន សែន ចាក់អង្រែ " ស្ថិតនៅក្នុង សង្កាត់ ចាក់អង្រែក្រោម ខណ្ឌ មានជ័យ រាជធានីភ្នំពេញ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ សង្កាត់ ចាក់អង្រែក្រោម ខណ្ឌ មានជ័យ ចុះថ្ងៃទី ២២ កុម្ភៈ ២០០៧ ដោយមានយោបល់ឯកភាព ពីមន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល រាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ស ំ រ េ ច

ប្រការ ១ : អនុញ្ញាតឱ្យប្តូរឈ្មោះ អនុវិទ្យាល័យ " ចាក់អង្រែ " បច្ចុប្បន្ន ទៅជា អនុវិទ្យាល័យ " ហ៊ុន សែន ចាក់អង្រែ " ស្ថិតនៅក្នុង សង្កាត់ ចាក់អង្រែក្រោម ខណ្ឌ មានជ័យ រាជធានីភ្នំពេញ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា រាជធានីភ្នំពេញ និងនាយកអនុវិទ្យាល័យសាមីមាន ភារកិច្ច រៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ ... ឆ្នាំ២០០...

បណ្ឌិត កុល ពាញ

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាក្រុងភ្នំពេញ " ដើម្បីជាពត៌មាន "
- ដូចប្រការ៣
- កាលប្បវត្តិ-ឯកសារ ឱ.មចទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១២៨៥ អយក.ប្រក

ប្រ កា ស

ស្តីពីការបើកអនុវិទ្យាល័យ " អន្លង់ក្អែបលេខ "

ស្ថិតនៅក្នុង ឃុំ អូរបាក់រទេះ ស្រុក កំពង់សិលា ខេត្ត កោះកុង

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកម្រិត១- កម្រិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ អូរបាក់រទេះ ស្រុក កំពង់សិលា ចុះថ្ងៃទី ១៣ វិច្ឆិកា ២០០៦ ដោយមានយោបល់ ឯកភាព ពីមន្ទីរ អប់រំ យុវជន និង កីឡា និង អភិបាល ខេត្ត កោះកុង
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ស ម្រេ ច

ប្រការ ១ : អនុញ្ញាតឱ្យបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ " **អន្លង់ក្អែបលេខ** " ស្ថិតនៅក្នុងឃុំ អូរបាក់រទេះ ស្រុក កំពង់សិលា ខេត្ត កោះកុង ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២ : អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃអនុវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃអនុវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត កោះកុង និងនាយកអនុវិទ្យាល័យសាមីមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ១៥ ខែ ... ឆ្នាំ២០០៧

កន្លែងទទួល:

- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- -ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាព័ត៌មាន "
- -សាលាខេត្ត កោះកុង " ដើម្បីជាពត៌មាន"
- -ដូចប្រការ៤
- -កាលប្បវត្តិ-ឯកសារ នា.មចទ

បណ្ឌិត ក្រុយ ឆេង

Monysetha/NewSchool.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និង កីឡា

លេខ: ១៤៨៦ អយក.ប្រក

ប្រ កា ស

ស្តីពីការពង្រីកអនុវិទ្យាល័យ " **មហាមន្ត្រី ហ៊ុន សែន មហាសៀក** " ទៅជា

វិទ្យាល័យ " **មហាមន្ត្រី ហ៊ុន សែន មហាសៀក** "

ស្ថិតនៅក្នុង ឃុំ មហាខ្ញូង ស្រុក កោះសូទិន ខេត្ត កំពង់ចាម

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ០៧០៤-១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ កក្កដា ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យ លេខ ២១ អនក្រ-បក ចុះថ្ងៃទី២៣ មីនា ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និង កីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទម ចុះថ្ងៃទី ០២ មេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១- កំរិត២
- យោងលិខិតស្នើសុំរបស់សហគមន៍ ឃុំ មហាខ្ញូង ស្រុក កោះសូទិន ចុះថ្ងៃទី ២៨ មករា ២០០៧ ដោយមានយោបល់ ឯកភាព ពី មន្ទីរអប់រំ យុវជន និង កីឡា និង អភិបាល ខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ

ស ម្រេ ច

ប្រការ ១ : អនុញ្ញាតឱ្យពង្រីកអនុវិទ្យាល័យ " **មហាមន្ត្រី ហ៊ុន សែន មហាសៀក** " បច្ចុប្បន្ន ទៅជាវិទ្យាល័យ " **មហាមន្ត្រី ហ៊ុន សែន មហាសៀក** " ស្ថិតនៅក្នុង ឃុំ មហាខ្ញូង ស្រុក កោះសូទិន ខេត្តកំពង់ចាម ចាប់ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

ប្រការ ២ : វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និងនាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗមួយចំនួនទៀតតាមអង្គការលេខនៃវិទ្យាល័យ ។

ប្រការ ៣ : នាយក-នាយករង និងបុគ្គលិកសិក្សានៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្តកំពង់ចាម នាយកវិទ្យាល័យ សាមីមាន ភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ ... ឆ្នាំ២០០

បណ្ឌិត កឹុល ផេង

កន្លែងទទួល:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ចាម "ដើម្បីជាពត៌មាន"
- ដូចប្រការ៥
- កាលប្បវត្តិ-ឯកសារ នា.មចទ

Monvsetha / Increase School.doc